***NoN POTEST Rex Gratiam facere cum Injuria et Damno ALIORUM* (3 Inst. 236.)**

The king cannot confer a favor on one subject which occasions injury and loss to others.

It is an ancient and constant rule of law, that the king's grants are invalid when they destroy or derogate from rights, privileges, or immunities previously vested in another subject: the Crown, for example, cannot enable a subject to erect a market or fair so near that of another person as to affect his interests therein. Nor can the king grant the same thing in possession to one, which he or his progenitors have granted to another. If the king's grant reciting that A. holds the manor of Blackacre for life, grants it to B. for life; in this case the law implies that the second grant is to take effect after the determination of the first. And if the king, being tenant for life of certain land, grant it to one and his heirs, the grant is void, for the king has taken upon himself to grant a greater estate than he lawfully could grant.

On the same principle, the crown cannot at common law pardon an offence against a penal statute after information brought, for thereby the informer has acquired a private property in his part of the penalty. Nor can the king pardon a private nuisance while it remains unredressed, or so as to prevent an abatement of it, though afterwards he may remit the fine; and the reason is that, though the prosecution is vested in the Crown, to avoid multiplicity of suits, yet (during its continuance) this offence savors more of the nature of a private injury to each individual in the neighborhood, than of a public wrong. So, if the king grant lands, forfeited to him upon a conviction for treason, to a third person, he cannot afterwards, by his grant, devest the property so granted in favor of the original owner.

(pages 4-5 from A Selection of Legal Maxims, 1874)

**ព្រះមហាក្សត្រមិនអាចប្រទានការអនុគ្រោះណាមួយដែលបង្កឲ្យមានរបួសនិងការខាតបង់ដល់អ្នកដទៃឡើយ។**

វាជាក្បួនច្បាប់បុរាណនិងជាបន្តរហូតថា ការប្រទានរបស់ព្រះមហាក្សត្រ គឺមិនត្រឹមត្រូវទេ នៅពេលដែលវាបំផ្លាញឬបន្ថយសិទ្ធិ អភ័យឯកសិទ្ធិឬឯកសិទ្ធិដែលបានប្រគល់ឲ្យប្រជាជនម្នាក់ផ្សេងទៀតរួចហើយ។ ព្រះមហាក្សត្រ មិនអាចអនុញ្ញាតឲ្យប្រជាជនម្នាក់បង្កើតផ្សារ ឬពិព័រណ៌ដែលនៅជិតផ្សាររបស់អ្នកដទៃពេក រហូតប៉ះពាល់ដល់ផលប្រយោជន៍របស់គេឡើយ។ ព្រះមហាក្សត្រ ក៏មិនអាចប្រទានវត្ថុដូចគ្នា ដែលមានក្នុងកម្មសិទ្ធិដល់អ្នកមួយបានទេ ខណៈដែលព្រះអង្គ ឬបុព្វបុរសរបស់ព្រះអង្គ បានប្រទានដល់អ្នកផ្សេងរួចហើយ។ ប្រសិនបើការប្រទានរបស់ព្រះមហាក្សត្រ បានរៀបរាប់ថា*ក* កាន់កាប់តំបន់អចលនទ្រព្យ Blackacreសម្រាប់មួយជីវិតហើយប្រទានវាទៅដល់ *ខ* សម្រាប់មួយជីវិតនោះ ច្បាប់ចែងថាការប្រទានលើកទីពីរនេះ នឹងត្រូវមានប្រសិទ្ធភាពក្រោយពេល ដែលការប្រទានលើកទីមួយបានផុតកំណត់។ ប្រសិនបើព្រះមហាក្សត្រជាអ្នកកាន់កាប់ដីធ្លីសម្រាប់មួយជីវិត ហើយប្រទានវាទៅអ្នកមួយ និងអ្នកស្នងរបស់គេ នោះការប្រទាននោះគឺទុកជាមោឃៈ ព្រោះព្រះមហាក្សត្រ

បានសន្មតិថានឹងប្រទាននូវកម្មសិទ្ធិធំជាងអ្វីដែលព្រះអង្គ អាចប្រទានបានតាមផ្លូវច្បាប់។

ដោយផ្អែកលើគោលការណ៍ដូចគ្នានេះដែរ ព្រះមហាក្សត្រ តាមច្បាប់កំមុនឡូ មិនអាចលើកលែងទោសបទល្មើស ក្រោយពេលដែលមានការជូនដំណឹងអំពីបទចោទរួចហើយបានទេ ព្រោះអ្នកផ្តល់ដំណឹងបានទទួលកម្មសិទ្ធិឯកជនរួចហើយលើចំណែកនៃទោសទណ្ឌ។ ព្រះមហាក្សត្រ ក៏មិនអាចលើកលែងទោសដល់ភាពរំខានឯកជន ខណៈដែល វានៅមិនទាន់ត្រូវបានដោះស្រាយ ឬដើម្បីការពារការបញ្ចប់វាបានទេ ទោះបីជាក្រោយមកព្រះអង្គ អាចលើកលែងការផាកពិន័យក៏ដោយ។ ហេតុផលគឺថា ទោះបីជាការចោទប្រកាន់ ត្រូវបានប្រគល់ទៅព្រះមហាក្សត្រ ដើម្បីចៀសវាងភាពស្មុគស្មាញនៃបណ្តឹងក៏ដោយក៏បទល្មើសនេះ(ក្នុងកំឡុងពេលដែលវានៅបន្ត) ទំនងជាវាបានបង្ករបួសដល់បុគ្គលម្នាក់ៗក្នុងសង្កាត់ ជាងជាកំហុសលើសាធារណៈទទៅទៀត។ ដូចគ្នានេះដែរ ប្រសិនបើព្រះមហាក្សត្រ ប្រទានដីធ្លី ដែលត្រូវបានរឹបអូសពីបទក្បត់ជាតិ ទៅឲ្យអ្នកទីបី ព្រះអង្គមិនអាច ក្រោយមក តាមរយៈការប្រទានរបស់ព្រះអង្គ ដកហូតកម្មសិទ្ធិ ដែលបានប្រទានដូច្នេះក្នុងការពេញចិត្តដល់ម្ចាស់ដើមឡើយ។

(ដកស្រង់ពីទំព័រទី 4-5 នៃសៀវភៅ A Selection of Legal Maxims, ឆ្នាំ 1874)